# កិច្ចព្រមព្រៀងសមិទ្ធកម្ម

# រវាង

# ប្រធានអនុកម្មវិធី១.៣

# និង

# ប្រធានកម្មវិធីទី១

# ស្តីពី

# ការអនុវត្តថវិកាសមិទ្ធកម្ម

# ឆ្នាំ២០២៥

# កិច្ចព្រមព្រៀងសមិទ្ធកម្ម រវាង
# ប្រធានអនុកម្មវិធីទី១.៣ និងប្រធានកម្មវិធីទី១

កិច្ចព្រមព្រៀងនេះធ្វើឡើងរវាង **ប្រធានអនុកម្មវិធី** និង **ប្រធានកម្មវិធី** ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ដែលត្រូវបានប្រកាសដាក់ឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២២៤/០០៨ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤ ក្នុងគោលដៅអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងក្នុងគោលបំណងលើកកម្ពស់ការចូលរួមអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ឬហៅកាត់ថា **"ថវិកាសមិទ្ធកម្ម"** ក្នុងស្មារតីតម្រូវឱ្យមានការវាស់វែងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃកម្មវិធី តាមរយៈសូចនាករសមិទ្ធកម្ម ដោយផ្សារភ្ជាប់រវាងលទ្ធផលក្នុងឆ្នាំ និងអាទិភាពគោលនយោបាយសម្រាប់ធ្វើការសម្រេចចិត្តលើការវិភាជន៍ថវិកា ឬធនធានហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាចុះកិច្ចព្រមព្រៀងក្នុងការអនុវត្ត ដូចមានចែងក្នុងប្រការខាងក្រោម៖**

**ប្រការ១៖ វិសាលភាពការងារ និងតម្លៃកិច្ចព្រមព្រៀង**

ប្រធានអនុកម្មវិធី យល់ព្រមទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុ ក្រោមការពិនិត្យនិងសម្រេចរបស់ប្រធានកម្មវិធី សម្រាប់ការអនុវត្តអនុកម្មវិធី និងចង្កោមសកម្មភាពចំនួន០២ ដែលមានតម្លៃទឹកប្រាក់សរុបចំនួន ៧ ៤០៩,៦លានរៀល (ប្រាំពីរពាន់ បួនរយប្រាំបួនលាន ប្រាំមួយរយពាន់រៀល) ជាតម្លៃនៃកិច្ចព្រមព្រៀង។ អនុកម្មវិធី និងចង្កោមសកម្មភាពទាំង០២ មានដូចខាងក្រោម៖

អនុកម្មវិធីទី១.៣៖ ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំមធ្យមសិក្សា
តម្រូវការទឹកប្រាក់សរុប ៧ ៤០៩,៦លានរៀល
(ប្រាំពីរពាន់ បួនរយប្រាំបួនលាន ប្រាំមួយរយពាន់រៀល)

ចង្កោមសកម្មភាពទី១.៣.១៖ បង្កើនការចូលរៀននៅមធ្យមសិក្សា និងជួយសិស្សរៀនមានសមត្ថភាពបញ្ញាល្អប្រសើរ និងរៀនចប់នៅមធ្យមសិក្សា
តម្រូវការទឹកប្រាក់សរុប ៧ ៣៩៤,៧លានរៀល
(ប្រាំពីរពាន់ បីរយកៅសិបបួនលាន ប្រាំពីររយពាន់រៀល)

ចង្កោមសកម្មភាពទី១.៣.២៖ ការលើកកម្ពស់ការងារគ្រប់គ្រងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
តម្រូវការទឹកប្រាក់សរុប ១៤,៩លានរៀល
(ដប់បួនលាន ប្រាំបួនរយពាន់រៀល)

អនុកម្មវិធី និងចង្កោមសកម្មភាពនីមួយៗខាងលើនេះ នឹងត្រូវបានបញ្ជាក់លម្អិតនៅក្នុងឧបសម្ព័ន្ធទី១ នៃកិច្ចព្រមព្រៀងនេះ។

ប្រការ២៖ សូចនាករសមិទ្ធកម្ម

ដើម្បីវាស់វែងអនុកម្មវិធី និងចង្កោមសកម្មភាព ដូចមានចែងក្នុងប្រការ១ អនុកម្មវិធីបានព្រមព្រៀងបង្កើតសូចនាករសមិទ្ធកម្មចំនួន០៣ មានបញ្ជាក់ខាងក្រោម និងមាននៅក្នុងឧបសម្ព័ន្ធទី២។

អនុកម្មវិធីទី១.៣៖ អាចសម្រេចបាន ដោយផ្អែកលើសូចនាករសមិទ្ធកម្មចំនួន០៣។

ចង្កោមសកម្មភាពទី១.៣.១៖ អាចសម្រេចបាន ដោយផ្អែកលើសូចនាករលទ្ធផលក្នុងឆ្នាំចំនួន០៨។

ចង្កោមសកម្មភាពទី១.៣.២៖ អាចសម្រេចបាន ដោយផ្អែកលើសូចនាករលទ្ធផលក្នុងឆ្នាំចំនួន០១។

| គោលនយោបាយ/គោលបំណងកិច្ចព្រមព្រៀង | សូចនាករគន្លឹះ | គោលដៅ (លទ្ធផលក្នុងឆ្នាំ ២០២៥) |
|---|---|---|
| គោលបំណងអនុកម្មវិធីទី១.៣៖ ធានាការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញ ដោយពង្រីកវិសាលភាពចំណេះដឹងពីបឋមសិក្សា និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បន្តការសិក្សា។ | សូចនាករទី១៖ ចំនួនសាលាមធ្យមសិក្សាចំណេះទូទៅសម្រេចបានស្តង់ដាសាលារៀនមធ្យមសិក្សាគំរូ | ១៦៨ សាលា |
| | មធ្យមសិក្សាបឋមភូមិគំរូ | ៦៥ សាលា |
| | មធ្យមសិក្សាទុតិយភូមិគំរូ | ១០៣ សាលា |
| | សូចនាករទី២៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សា | |
| | មធ្យមសិក្សាបឋមភូមិ | ៦៧,៤ ភាគរយ |
| | មធ្យមសិក្សាទុតិយភូមិ | ៤៦,៣ ភាគរយ |
| | សូចនាករទី៣៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សា | |
| | មធ្យមសិក្សាបឋមភូមិ | ៦២,២ ភាគរយ |
| | មធ្យមសិក្សាទុតិយភូមិ | ៤០,៩ ភាគរយ |
| ចង្កោមសកម្មភាពទី១.៣.១៖ បង្កើនការចូលរៀននៅមធ្យមសិក្សា និង ជួយសិស្សរៀនមានសមត្ថភាព បញ្ញាល្អប្រសើរ និងរៀនចប់នៅមធ្យមសិក្សា | សូចនាករទី១៖ អត្រាឆ្លងភូមិសិក្សា | |
| | បឋមសិក្សា ទៅមធ្យមសិក្សាបឋមភូមិ | ៨៦,២ ភាគរយ |
| | មធ្យមសិក្សាបឋមភូមិ ទៅមធ្យមសិក្សាទុតិយភូមិ | ៨០,៦ ភាគរយ |
| | សូចនាករទី២៖ អត្រាគង់វង្ស | |
| | មធ្យមសិក្សាបឋមភូមិ | ៥៥,៦ ភាគរយ |
| | មធ្យមសិក្សាទុតិយភូមិ | ៣៦,១ ភាគរយ |
| | សូចនាករទី៣៖ អត្រាបោះបង់នៅមធ្យមសិក្សា | |
| | មធ្យមសិក្សាបឋមភូមិ | ១៥ ភាគរយ |
| | មធ្យមសិក្សាទុតិយភូមិ | ១៣,៣ ភាគរយ |

| | | |
|---|---|---|
| | សូចនាករទី៤៖<br>អត្រាត្រួតថ្នាក់នៅមធ្យមសិក្សា | |
| | មធ្យមសិក្សាបឋមភូមិ | ៣,២ |
| | មធ្យមសិក្សាទុតិយភូមិ | ១,៣ |
| | សូចនាករទី៥៖<br>ចំនួនសិស្សក្រីក្រនៅមធ្យមសិក្សាបឋមភូមិ<br>ទទួលបានអាហារូបករណ៍ | ១១៩ ៩៦១<br>នាក់ |
| | សូចនាករទី៦៖<br>ចំនួនសិស្សក្រីក្រនៅមធ្យមសិក្សាទុតិយភូមិ<br>ទទួលបានអាហារូបករណ៍ | ១៣ ១១៧<br>នាក់ |
| | សូចនាករទី៧៖<br>ចំនួនសាលាមធ្យមសិក្សាអនុវត្តសកម្មភាព<br>ក្រៅម៉ោងសិក្សា | ៣០ សាលា |
| | សូចនាករទី៨៖<br>ចំនួនសាលារៀនជំនាន់ថ្មី | ១១ សាលា |
| ចង្កោមសកម្មភាពទី១.៣.២៖ ការលើកកម្ពស់ការងារគ្រប់គ្រងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | សូចនាករទី១៖<br>ចំនួនសាលារៀនដែលមានគណៈកម្មការ<br>គ្រប់គ្រងសាលារៀនដំណើរការសកម្ម | ៨៥៦ សាលា |

## ប្រការ៣៖ កាលបរិច្ឆេទចាប់ផ្ដើម និងបញ្ចប់ "អនុកម្មវិធី និងចង្កោមសកម្មភាព"

ប្រធានអនុកម្មវិធី ត្រូវចាប់ផ្ដើមអនុវត្តអនុកម្មវិធី និងចង្កោមសកម្មភាព ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ ២០២៥ និងត្រូវបញ្ចប់តាមឆ្នាំសារពើពន្ធ ដែលត្រូវនឹងថ្ងៃទី៣១ ខែធ្នូ ឆ្នាំដដែលខាងលើ។

## ប្រការ៤៖ ការផ្តល់ធនធានហិរញ្ញវត្ថុ

ប្រធានកម្មវិធីមានកាតព្វកិច្ចផ្តល់ធនធានហិរញ្ញវត្ថុជូនប្រធានអនុកម្មវិធី ក្នុងនាមអង្គភាពថវិកា ឬអង្គភាពថវិកាផ្ទេរសិទ្ធិ ដើម្បីអនុវត្តអនុកម្មវិធីតាមស្មារតីនៃកិច្ចព្រមព្រៀងរវាងប្រធានកម្មវិធី និងក្រសួង-ស្ថាប័នសាមី ដោយអនុលោមទៅតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ជាពិសេសបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

ការបង្វែរ បង្កក លុបចោល និងបន្ថែមឥណទាន តាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកាសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ប្រព័ន្ធហិរញ្ញវត្ថុ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

## ប្រការ៥៖ កាតព្វកិច្ចអនុវត្តអនុកម្មវិធី ចង្កោមសកម្មភាព និងធនធានហិរញ្ញវត្ថុ

ប្រធានអនុកម្មវិធី មានកាតព្វកិច្ចអនុវត្តអនុកម្មវិធី និងចង្កោមសកម្មភាព ទៅតាមធនធានហិរញ្ញវត្ថុដែលប្រធានកម្មវិធី បានព្រមព្រៀង និងផ្តល់ជូនតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

ប្រការ៦៖ របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្ម

ប្រធានអនុកម្មវិធី មានភារកិច្ចប្រមូលព័ត៌មាន ពិនិត្យ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្ម លើអនុកម្មវិធី និងចង្កោមសកម្មភាព ដែលមានសូចនាករនិងគោលដៅដែលបានកំណត់ ដើម្បីជូនប្រធានកម្មវិធីដែលទទួលបន្ទុកកម្មវិធី ប្រមូលធ្វើរបាយការណ៍របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្មក្នុងកម្រិតកម្មវិធី ស្របតាមច្បាប់ នីតិវិធីហិរញ្ញវត្ថុ និងរបបរបាយការណ៍ជាធរមាន។

ប្រការ៧៖ ឯកសារឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀង

ឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ គឺជាចំណែកទាំងស្រុងកិច្ចព្រមព្រៀងនេះ។

រាល់បញ្ហាពាក់ព័ន្ធនឹងការអនុវត្តការងារ ភាគីទាំងពីរត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងផ្ញើមកកាន់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានអាសយដ្ឋាន ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬក្រសួងអប់រំ យុវជន និងកីឡា ដែលមានអាសយដ្ឋាន អគារលេខ ៨០ មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ប្រការ៨៖ និសានវាទ

ប្រធានអនុកម្មវិធី ចុះហត្ថលេខា ដើម្បីបំពេញភាតព្វកិច្ចជានាគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈស្របតាមសមិទ្ធកម្ម។ ចំណែកប្រធានកម្មវិធី ចុះហត្ថលេខាក្នុងនាមជាភាគីផ្តល់ធនធានហិរញ្ញវត្ថុបន្តទៅដល់ប្រធានអនុកម្មវិធី។

ភាគីទាំងពីរមានភារកិច្ចអនុវត្តកិច្ចព្រមព្រៀងឱ្យបានម៉ឺងម៉ាត់។ កិច្ចព្រមព្រៀងនេះត្រូវធ្វើជាភាសាខ្មែរ ចំនួន បួន (៤) ច្បាប់ដើម មានតម្លៃដូចគ្នា និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ព្រមទាំងរក្សាទុកនៅ៖

- ប្រធានកម្មវិធី ចំនួន ១ ច្បាប់
- ប្រធានអនុកម្មវិធី ចំនួន ១ ច្បាប់
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន ១ ច្បាប់
- ឯកសារ-កាលប្បវត្តិ ចំនួន ១ ច្បាប់។

ជាសក្ខីភាព អ្នកតំណាងស្របច្បាប់ដែលរាជរដ្ឋាភិបាលបានប្រគល់អំណាចត្រឹមត្រូវ មានសិទ្ធិគ្រប់គ្រាន់ក្នុងការចុះហត្ថលេខា។

កិច្ចព្រមព្រៀងនេះ ធ្វើឡើងនៅរាជធានីភ្នំពេញ ថ្ងៃអង្គារ ២កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹង ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។

| ប្រធានកម្មវិធីទី១ | ប្រធានអនុកម្មវិធីទី១.៣ |
|---|---|
| អ៊ុង ជិនណា | ជា ឌុធ |